**Governance and Policy Committee**
**International School of Phnom Penh**
88 Hun Neang Boulevard, P.O. Box 138, Phnom Penh, Cambodia

AGM-April 29, 2020

# របាយការណ៍របស់គណៈកម្មាធិការអភិបាលកិច្ច និងគោលនយោបាយគ្របដណ្តប់លើឆ្នាំសិក្សា ២០១៩-២០២០

## វិសាលភាព និងអាណត្តិរបស់គណៈកម្មាធិការ

នៅខែមិថុនា ឆ្នាំ២០១៩ ក្រុមប្រឹក្សាភិបាលរបស់សាលាអន្តរជាតិភ្នំពេញ ត្រូវបានបោះឆ្នោតឱ្យច្របាច់បញ្ចូលគណៈកម្មាធិការអភិបាលកិច្ច (GC) ជាមួយគណៈកម្មាធិការគោលនយោបាយ (PC) ទៅជាគណៈកម្មាធិការអភិបាលកិច្ច និងគោលនយោបាយ (GPC) តែមួយសម្រាប់ឆ្នាំសិក្សា ២០១៩-២០២០ អាស្រ័យដោយលក្ខណៈបំពេញបន្ថែមគ្នាលើអាណត្តិ និងការងាររបស់គណៈកម្មាធិការទាំងពីរនេះ។ ភារកិច្ចជាក់លាក់របស់ GPC ត្រូវបានកំណត់ក្នុងអំឡុងពេលកិច្ចប្រជុំបូកសរុបរបស់ក្រុមប្រឹក្សាភិបាល ក្នុងខែកញ្ញា ឆ្នាំ ២០១៩។ ចាប់ពីខែកញ្ញា ឆ្នាំ ២០១៩ ដល់ខែមីនា ឆ្នាំ ២០២០ GPC បានជួបប្រជុំចំនួនប្រាំពីរលើក។ ទម្រង់នៃ GC-PC ដែលបានច្របាច់បញ្ចូលគ្នា គឺមានប្រសិទ្ធភាព ហើយ GPC សូមផ្តល់អនុសាសន៍ឱ្យគណៈកម្មាធិការទាំងនេះបន្តរួមគ្នាជា GPC ក្នុងឆ្នាំ ២០២០-២១។

ការគ្របដណ្តប់លើការទទួលខុសត្រូវរបស់ GC និង PC ដូចមានពិពណ៌នាក្នុងសៀវភៅណែនាំគោលនយោបាយរបស់សាលាអន្តរជាតិភ្នំពេញ GPC បានសម្របសម្រួលក្រុមប្រឹក្សាភិបាលរបស់សាលាអន្តរជាតិភ្នំពេញក្នុងការសម្រេចចិត្តផ្អែកលើព័ត៌មានត្រឹមត្រូវស្តីពីរចនាសម្ព័ន្ធផ្នែកច្បាប់ ផ្នែកស្ថាប័ន និងគោលនយោបាយរបស់សាលាអន្តរជាតិភ្នំពេញ។ ដោយឡែក GPC ដឹកនាំការវាយតម្លៃ ការអភិវឌ្ឍ ការជ្រើសរើស និងការបោះឆ្នោតសម្រាប់ក្រុមប្រឹក្សាភិបាលរបស់សាលាអន្តរជាតិភ្នំពេញ ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពលើគោលនយោបាយ នីតិវិធី និងរចនាសម្ព័ន្ធរបស់សាលា និងក្រុមប្រឹក្សាភិបាល អភិវឌ្ឍ និងតាមដានបន្តលើគោលដៅរបស់ក្រុមប្រឹក្សាភិបាល និងនាយកសាលា និងសម្របសម្រួលដល់កិច្ចប្រជុំទូទៅប្រចាំឆ្នាំ (AGM) ក្នុងខែមេសា រៀងរាល់ឆ្នាំ។

## ការរៀបចំរចនាសម្ព័ន្ធផ្នែកច្បាប់របស់សាលាអន្តរជាតិភ្នំពេញឡើងវិញ

រចនាសម្ព័ន្ធផ្នែកច្បាប់ និងអភិបាលកិច្ចរបស់សាលាអន្តរជាតិភ្នំពេញ បានលូតលាស់តាមលក្ខណៈប្រក្រតី ដើម្បីឆ្លើយតបចំពោះសេចក្តីត្រូវការដែលមានការវិវត្តជាប្រចាំរបស់សាលា ដែលកំពុងមានការលូតលាស់។ ព្រមជាមួយការកសាងមណ្ឌលសិក្សារបស់សាលាអន្តរជាតិភ្នំពេញ រចនាសម្ព័ន្ធក៏ឈានទៅមានភាពស្មុគស្មាញកាន់តែច្រើនឡើង ដោយអង្គភាពសាជីវកម្មត្រូវបានបង្កើតឡើងដើម្បីទទួលបានកម្ចី និងធ្វើជាម្ចាស់កម្មសិទ្ធិដីធ្លី។ អង្គភាពសាជីវកម្មក៏ត្រូវបានបង្កើតឡើងសម្រាប់សាលាអន្តរជាតិភ្នំពេញនៅក្នុងសហរដ្ឋអាមេរិច ក្នុងចេតនាដើម្បីទទួលបានកម្ចីរបស់សហរដ្ឋអាមេរិចផងដែរ។ នៅទីបំផុត អង្គភាពនេះពុំបានឈានដល់ទីបញ្ចប់ទេ។ ក្រុមប្រឹក្សាភិបាល និងនាយកសាលាបច្ចុប្បន្នបាន

សម្រេចចិត្តប្រាប់អង្គភាពផ្នែកច្បាប់ផ្សេងៗជាច្រើនទៅជារចនាសម្ព័ន្ធដែលមានលក្ខណៈសាមញ្ញ និងសមស្របតាមគោលបំណង ដែលស្ថិតក្រោមការគ្រប់គ្រងបានគ្រប់ពេល ពីសំណាក់សមាគមសាលាអន្តរជាតិភ្នំពេញ តាមរយៈក្រុមប្រឹក្សាភិបាល និងនាយកសាលា។ ដើម្បីអាចធ្វើបែបនេះបាន GPC ជាដំបូងបានធ្វើការដើម្បីស្វែងយល់ឱ្យបានពេញលេញអំពីរចនាសម្ព័ន្ធផ្នែកច្បាប់ជាធរមាន អភិវឌ្ឍផែនការសម្រាប់រចនាសម្ព័ន្ធផ្នែកច្បាប់ថ្មី បានទទួលយោបល់ផ្នែកច្បាប់ពីទីប្រឹក្សាច្បាប់មានមូលដ្ឋាននៅប្រទេសកម្ពុជារបស់យើង និងចាប់ផ្តើមបង្កើតរចនាសម្ព័ន្ធថ្មីស្របពេលដែលយើងបានកែសម្រួលរចនាសម្ព័ន្ធពីមុនមកដែលមានលក្ខណៈលើសតម្រូវការ រួមទាំងសាជីវកម្មដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិចនោះផងដែរ។ ដំណើរការទាំងអស់នេះ គឺកំពុងប្រព្រឹត្តទៅនៅក្នុងពេលយើងកំពុងសរសេររបាយការណ៍នេះ។ រចនាសម្ព័ន្ធផ្នែកច្បាប់សមស្របត្រូវបានបង្កើតឡើង និងរក្សា ដែលអនុញ្ញាតឱ្យសាលាអន្តរជាតិភ្នំពេញអាចបំពេញគោលបំណង និងអាណត្តិរបស់ខ្លួន ដើម្បីបានទទួលកម្ចី និងធ្វើជាម្ចាស់កម្មសិទ្ធិដីធ្លី គឺជាផ្នែកមួយនៃផែនការយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំថ្មី ហេតុនេះហើយគឺផែនការយុទ្ធសាស្ត្រនេះនឹងត្រូវបានពិនិត្យឡើងវិញ និងរាយការណ៍ជារៀងរាល់ឆ្នាំ។

## <u>ការកែសម្រួលលើធម្មនុញ្ញរបស់សាលា</u>

ដូចគ្នាជាមួយរចនាសម្ព័ន្ធផ្នែកច្បាប់ដែរ ធម្មនុញ្ញរបស់សាលាអន្តរជាតិភ្នំពេញត្រូវបានកែសម្រួលជាបន្តបន្ទាប់។ ក្នុងឆ្នាំ ២០២០-២១ ចាំបាច់ត្រូវមានការកែសម្រួលឡើងវិញជាថ្មី ដើម្បីបន្សីជាមួយរចនាសម្ព័ន្ធផ្នែកច្បាប់ថ្មី។ GPC បានចាប់ផ្តើមសរសេរព្រាងការសម្រួលឡើងវិញលើធម្មនុញ្ញរបស់សាលាអន្តរជាតិភ្នំពេញ ដាក់បញ្ចូលទៅក្នុងលក្ខន្តិកៈ និងមាត្រានានា។ នៅពេលរចនាសម្ព័ន្ធផ្នែកច្បាប់ថ្មីត្រូវបានបញ្ចប់ជាស្ថាពរ ធម្មនុញ្ញកែសម្រួលឡើងវិញក៏នឹងត្រូវបង្ហើយជាស្ថាពរ ធ្វើបទបង្ហាញ និងបោះឆ្នោតដោយសមាគមសាលាអន្តរជាតិភ្នំពេញ នៅក្នុងកិច្ចប្រជុំពិសេសរបស់សមាគម ដែលនឹងត្រូវកោះប្រជុំដោយក្រុមប្រឹក្សាភិបាល (មាត្រា ៨.២ នៃធម្មនុញ្ញបច្ចុប្បន្ន)។ កិច្ចប្រជុំពិសេសនេះនឹងត្រូវធ្វើឡើងនៅក្នុងកាលបរិច្ឆេទសមស្របនាពេលអនាគត ជាបឋមគឺត្រូវបានកំណត់ថា នឹងត្រូវធ្វើឡើងនៅក្នុងវគ្គសិក្សាទីមួយនៃឆ្នាំសិក្សា ២០២០-២១។

## <u>ការពិនិត្យឡើងវិញផ្នែកគោលនយោបាយ</u>

គណៈកម្មាធិការគោលនយោបាយពិនិត្យឡើងវិញជាប្រចាំលើផ្នែកផ្សេងៗនៃសៀវភៅណែនាំគោលនយោបាយរបស់សាលាអន្តរជាតិភ្នំពេញ ដោយប្រើប្រាស់វិធីសាស្ត្រវិលជុំ ដើម្បីធានាឱ្យមានវដ្តនៃការកែសម្រួលឡើងវិញពេញលេញរៀងរាល់បីឆ្នាំម្តង។ ដោយមាននាយកសាលាថ្មី ធម្មនុញ្ញ និងរចនាសម្ព័ន្ធផ្នែកច្បាប់ ក្រុមប្រឹក្សាភិបាលបានសម្រេចចិត្តថា សៀវភៅណែនាំគោលនយោបាយគួរត្រូវបានកែសម្រួលឡើងវិញទាំងស្រុងក្នុងឆ្នាំ ២០២០-២១។ ដើម្បីធានាឱ្យ

បានថាមិនមានបញ្ហាច្បាស់ក្រឡែត ឬការមើលខុសត្រូវសម្រាប់ឆ្នាំសិក្សា ២០១៩-២០ ទេនោះ ក្នុងខែកញ្ញា ឆ្នាំ ២០១៩ GPC (បានទទួលការជួយជ្រោមជ្រែងពីសមាជិកក្រុមប្រឹក្សាភិបាលបន្ថែម) បានអានសៀវភៅណែនាំគោលនយោបាយទាំងស្រុង ដើម្បីពិនិត្យមើលឱ្យច្បាស់ថាមិនចាំបាច់ត្រូវមានការកែសម្រួលបន្ទាន់ណាត្រូវធ្វើឡើងឡើយ។ តាមរយៈលំហាត់នេះ សេចក្តីត្រូវការ និងចន្លោះខ្វះខាតជាច្រើនត្រូវបានកំណត់ឃើញ ហើយចំណុចទាំងអស់នេះនឹងត្រូវបានដោះស្រាយនៅក្នុងការកែសម្រួលគោលនយោបាយឆ្នាំ ២០២០-២១។

<u>គោលដៅរបស់ក្រុមប្រឹក្សាភិបាល និងនាយកសាលា</u>

GPC ទទួលខុសត្រូវក្នុងការធានាឱ្យបានថា ក្រុមប្រឹក្សាភិបាល និងនាយកសាលាកំណត់គោលដៅ និងធ្វើការឆ្លុះទៅសម្រេចគោលដៅទាំងអស់នោះជារៀងរាល់ឆ្នាំ។ គោលដៅរបស់នាយកសាលា ត្រូវបានអនុម័តនៅក្នុងរដូវត្រជាក់ឆ្នាំ ២០១៩ ហើយវឌ្ឍនភាពត្រូវបានពិនិត្យឡើងវិញនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល កាលពីខែមីនា ឆ្នាំ ២០២០។ គោលដៅរបស់ក្រុមប្រឹក្សាភិបាលត្រូវបានកំណត់នៅក្នុងកិច្ចប្រជុំបូកសរុបរបស់ក្រុមប្រឹក្សាភិបាលក្នុងខែកញ្ញា ឆ្នាំ ២០១៩ មានដូចខាងក្រោម៖

១. ក្រុមប្រឹក្សាភិបាលនឹងដាក់ស្នើធម្មនុញ្ញដែលបានធ្វើវិសោធនកម្មរួចជូន ដើម្បីសុំការផ្តល់សច្ចាប័ពីសមាគមតាមរយៈ AGM ដោយអមមកជាមួយនូវអនុសាសន៍ស្តីពីស្ថានភាពផ្នែកច្បាប់/រចនាសម្ព័ន្ធ។
២. ក្រុមប្រឹក្សាភិបាលនឹងបង្ហាញផែនការយុទ្ធសាស្ត្រដែលបានអនុម័តរួច ជូនដល់សមាជិករបស់សមាគមនៅក្នុង AGM។
៣. ក្រុមប្រឹក្សាភិបាលនឹងបំពេញផែនការអន្តរកាលដែលបានអនុម័តរួច ដើម្បីផ្តល់ការគាំទ្រជូនដល់ប្រធានសាលាថ្មី ដែលជួយធានាដល់ការបន្ត និងការផ្ទេរព័ត៌មាន នៅចុងឆមាសទី ១។

ក្នុងចំណោមគោលដៅទាំងអស់នេះ គោលដៅទី ២ និងទី ៣ ត្រូវបានសម្រេចជាស្ថាពររួចហើយ។ ចំពោះគោលដៅទី ១ យើងឃើញច្បាស់ថា ការរៀបចំរចនាសម្ព័ន្ធផ្នែកច្បាប់ឡើងវិញចាំបាច់ត្រូវការការកែសម្រួលធម្មនុញ្ញធ្វើឡើងជាមុនសិន។ ដោយហេតុនេះ GPC បានផ្តោតការយកចិត្តទុកដាក់លើការរៀបចំរចនាសម្ព័ន្ធផ្នែកច្បាប់ និងធ្វើសេចក្តីព្រាងការកែសម្រួលធម្មនុញ្ញដែលត្រូវបានរៀបចំឡើង។ ធម្មនុញ្ញនឹងត្រូវបានកែសម្រួល និងបង្ហើយជាស្ថាពរភ្លាមៗបន្ទាប់ពីការរៀបចំរចនាសម្ព័ន្ធផ្នែកច្បាប់ និងបង្ហាញជូនទៅសមាគមដើម្បីសុំការបោះឆ្នោត។ ស្វ័យវាយតម្លៃរបស់ក្រុមប្រឹក្សាភិបាលត្រូវបានគ្រោងធ្វើឡើងយោងទៅតាមកាលវិភាគកំណត់ក្នុងខែមេសា ឆ្នាំ ២០២០។

<u>កិច្ចប្រជុំទូទៅប្រចាំឆ្នាំ និងការបោះឆ្នោតសមាជិកក្រុមប្រឹក្សាភិបាល</u>

យោងតាមសំណើរបស់ GPC ក្រុមប្រឹក្សាភិបាលបានសម្រេចចិត្តនៅក្នុងខែកុម្ភៈ ឆ្នាំ ២០២០ ដើម្បីផ្លាស់ទៅរកការបោះឆ្នោតតាមអេឡិចត្រូនិច សម្រាប់ការបោះឆ្នោតសមាជិកក្រុមប្រឹក្សាភិបាល។ នៅក្នុងពេលសរសេររបាយការណ៍នេះ សហ្វវែរសម្រាប់ការបោះឆ្នោត គឺមានវត្តមាន និងត្រៀមរួចជាស្រេចដើម្បីបើកសម្រាប់ការបោះឆ្នោតនៅថ្ងៃទី ០៨ ខែមេសា។ សេចក្តីសម្រេចដើម្បីប្តូរទៅការបោះឆ្នោតតាមអេឡិចត្រូនិច គឺជាសេចក្តីសម្រេចចិត្តធ្វើឡើងដោយបន្ទាន់ ដោយហេតុថាការធ្វើបែបនេះនឹងអនុញ្ញាតឱ្យអាចបន្តការបោះឆ្នោតបាន បើទោះបីជាមណ្ឌលសាលារៀនត្រូវបានបិទជាបណ្តោះអាសន្ន មិនឱ្យសិស្ស និងឪពុកម្តាយចូលមក អាស្រ័យដោយការរាតត្បាតជំងឺកូវីដ១៩ ជាសកលក្តី។ ដូចគ្នានេះដែរ ការកោះប្រជុំ និងការប្រាព្ធកម្មវិធី AGM នឹងត្រូវធ្វើឡើងតាមអនឡាញ។ លទ្ធផលនៃការបោះឆ្នោតក្រុមប្រឹក្សាភិបាលថ្មី នឹងត្រូវប្រកាសនៅក្នុង AGM។ GPC ជួយធានាឱ្យប្រាកដថា មានការកោះប្រជុំ AGM ហើយរាល់ឯកសារ និងរបាយការណ៍ទាំងអស់ត្រូវបានរៀបចំ និងបញ្ជូន អនុលោមតាមធម្មនុញ្ញដែលមានជាធរមាន។

## <u>ចក្ខុវិស័យឆ្ពោះទៅមុខ៖ ឆ្នាំសិក្សា ២០២០-២១</u>

បន្ថែមលើការទទួលខុសត្រូវក្នុងវដ្តវិលជុំរបស់ GPC (ក្នុងការទទួលសមាជិកក្រុមប្រឹក្សាភិបាលថ្មីចូលមករួមការងារ ការកំណត់គោលដៅរបស់ក្រុមប្រឹក្សាភិបាល និងនាយកសាលា និងការតាមដានបន្តលើគោលដៅ ការរៀបចំការបោះឆ្នោត និង AGM) GPC ចាំបាច់ត្រូវ ១) បង្កើយដំណើរការរៀបចំរចនាសម្ព័ន្ធផ្នែកច្បាប់ឡើងវិញឱ្យចប់ជាស្ថាពរ ២) បំពេញការកែសម្រួលធម្មនុញ្ញ លក្ខន្តិកៈ និងមាត្រានានា ដើម្បីឱ្យសមស្របទៅតាមការរៀបចំរចនាសម្ព័ន្ធផ្នែកច្បាប់ឡើងវិញ និង ៣) កែសម្រួលសៀវភៅណែនាំគោលនយោបាយរបស់សាលាអន្តរជាតិភ្នំពេញ ដើម្បីបន្សុីជាមួយធម្មនុញ្ញ និងរចនាសម្ព័ន្ធអភិបាលកិច្ចថ្មី។ GPC ចាំបាច់ត្រូវអំពាវនាវឱ្យសមាគមសាលាអន្តរជាតិភ្នំពេញត្រូវបោះឆ្នោតលើធម្មនុញ្ញដែលបានកែសម្រួលឡើងវិញក្នុងអំឡុងឆ្នាំសិក្សា ២០២០-២១។

## <u>សមាជិក GPC</u>

GPC រួមមានសមាសភាព Clarisse Kehler Siebert (ប្រធាន), John Collins (ប្រធានក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការអភិបាលកិច្ច និងភាពជាអ្នកដឹកនាំ), Jenny Pearson (ប្រធានគណៈកម្មាធិការផែនការយុទ្ធសាស្រ្ត/អតីតប្រធានគណៈកម្មាធិការគោលនយោបាយ), Gareth Jones (រដ្ឋបាលរបស់សាលា ISPP), Emily Johnson (បុគ្គលិកសិក្សារបស់សាលា ISPP), Jen Grant (PCO)។ សូមថ្លែងអំណរគុណដល់អ្នកទាំងអស់គ្នាចំពោះការចូលរួមចំណែកជំនាញឯកទេស ពេលវេលា និងថាមពល។ ទាក់ទងជាមួយគណៈកម្មាធិការទាំងអស់របស់សាលាអន្តរជាតិ

ភ្នំពេញ កិច្ចប្រជុំ GPC ត្រូវបានប្រកាសនៅក្នុងសេចក្តីប្រកាសប្រចាំសប្តាហ៍របស់សាលាអន្តរជាតិភ្នំពេញ ហើយបើកទូលាយជូនដល់ឪពុកម្តាយរបស់សហគមន៍សាលាអន្តរជាតិភ្នំពេញទាំងអស់។

របាយការណ៍ GPC នេះត្រូវបានដាក់ជូនដោយក្តីគោរព ដោយ Clarisse Kehler Siebert, ប្រធានគណៈកម្មាធិការអភិបាលកិច្ច និងគោលនយោបាយរបស់សាលាអន្តរជាតិភ្នំពេញ ឆ្នាំ ២០១៩-២០។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០២០